# ព្រះរាជក្រឹត្យ

នស/រកត/០១១៨/០៦៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ និងថ្នាក់តាមអតីតភាពការងារ ជាករណីពិសេស ដល់មន្ត្រីរាជការ ០៦ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងធនធានទឹក និងឧតុនិយម ៖

| | | |
|---|---|---|
| ១- លោក **សរ គីមសាន្ត** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| ២- ឯកឧត្តម **ហ៊ៅល ភូនី** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៣- ឯកឧត្តម **ខុង មាស** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ៤- លោក **ស៊ិន ចិសិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៥- លោក **យ៉ាន់ សំរិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៦- លោក **ទិន ប៊ុនពៅ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៩២ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃអង្គារ ៧កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣៧៧.១៨០១.០៦៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៨